អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# កាលប្រវត្តិវិទ្យានៃសង្គ្រាមប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា

## *Chronologie du génocide cambodgien*

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១៤ មិថុនា ២០០៨

★★★ (១៩៦៧)

ខែមេសា - នៅក្នុងឆ្នាំ១៩៦៧ សម្តេចសីហនុបានចោទឧត្តមសេនីយ៍លន់-នល់ថាជា«ជនក្បត់» ជា«ស៊ីហារតូខ្មែរ» រួចហើយទ្រង់បានបញ្ជា ឲ្យឧត្តមសេនីយ៍ញ៉ឹក-ជូឡុង «ចាត់ការសម្ងេះ» លោកលន់-នល់ ដោយបង្កើតឲ្យមានគ្រោះថ្នាក់ក្រឡាប់ឡាន នៅថ្ងៃទី៨មេសា១៩៦៧ ។ លោកលន់-នល់មិនបានស្លាប់ទេ ប៉ុន្តែមានគ្រោះថ្នាក់ជាទម្ងន់... ហើយក៏បានលាលែងពីតំណែងនាយករដ្ឋមន្ត្រីនៅថ្ងៃដដែល ។ ជនដែលទទួលបន្ទុកបង្កើតរដ្ឋាភិបាលថ្មី គឺសម្តេចបវរសេដ្ឋាមហាសម្បត្តិសឺន-សាន ។ រដ្ឋាភិបាលថ្មីរបស់លោកមានឈ្មោះថា «រដ្ឋាភិបាលនៃការបង្រួបបង្រួមជាតិ»... នេះបានចំជាសំណើចចំអកនៃព្រេងវាសនា !!

ខែឧសភា - ដើម្បីធ្វើការបង្រួបបង្រួមជាតិនេះ ឯកឧត្តមសឺន-សានធ្លៀតឱកាសក្នុងប្រការដែលលន់-នល់បាត់បង់បុណ្យស័ក្តិអស់រលីង សហការជាមួយឧត្តមសេនីយ៍ញ៉ឹក-ជូឡុង ដែលកាន់អំណាចជាអគ្គបញ្ជាការកងទ័ព, ធ្វើការពិឃាតវង្គាលទៅលើប្រជាជននៅសំឡូត គឺបាញ់ប្រហារស្លាប់មនុស្សអស់១ម៉ឺន ( ១០,០០០នាក់) , នៅកន្លែងខ្លះមានការដុតភូមិចោលទាំងស្រុង (ចំនួនជនដែលគេពិឃាតនេះ គឺស្តេចសីហនុខ្លួនឯងបាននិយាយប្រាប់ទៅ Jean Lacouture នៅឆ្នាំ១៩៧២) ។ ដូចនេះសង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា បានត្រូវបង្កើតឡើងរួចហើយ ដែលជាស្នាដៃរបស់សឺន-សាននិងញ៉ឹក-ជូឡុង ដែលលួចធ្វើក្នុងនាមផ្ទាល់របស់ស្តេចសីហនុ ហើយក៏ទម្លាក់ទោសកំហុសនៃបទឧក្រិដ្ឋកម្មដ៏ធំធេងនេះ ទៅលើឧត្តមសេនីយ៍លន់-នល់ ។ ក្នុងប្រការនេះ សឺន-សានបានបាញ់មួយគ្រាប់ងាប់បាន«ចាបពីរ» ។ ហេតុអ្វីបានជាសឺន-សានធ្វើដូចនេះ, គឺមកពីសឺន-សានមិនមែនជាជនជាតិខ្មែរទេ... តែជាជនជាតិដែលមានដើមកំណើតជាយួន !!

★★★ តុលា ១៩៦៧

ក្រោមការណែនាំរបស់រដ្ឋមន្ត្រីទី១ស៊ីន-សាន (សម្តេចស៊ីន-សានហើយនិងសម្តេចប៉ែន-នុត មានមុខតំណែងជាពិសេសមួយដ៏មហាចម្លែក គឺគាត់ទាំងពីរជាទីប្រឹក្សា«ផ្ទាល់ខ្លួន»របស់ស្តេចសីហនុ - Conseillers privés du Chef de l'Etat - គឺបានពន្យល់ណែនាំស្តេចដោយរបៀប«ផ្ទាល់ខ្លួន» ពោលដោយសម្ងាត់ ឲ្យស្តេចសីហនុទទួលយកឯករាជ្យ ដោយបាត់បង់ទឹកដីកម្ពុជាក្រោមនៅឆ្នាំ១៩៤៩... រហូតដល់ណែនាំស្តេចឆ្កួតនេះ ឲ្យរត់ទៅចូលយួនហាណូយ នៅក្នុងខែមីនា១៩៧០ !!) ក្រោមការណែនាំរបស់ស៊ីន-សាន ស្តេចសីហនុក៏បានទទួលជំទាវហ្សាក់គីលីន-កេណ្ណឺឌី ឲ្យទៅធ្វើទស្សនកិច្ចនៅសៀមរាប-អង្គរ នៅខែតុលា១៩៦៧ (<u>កកន</u> ៖ ដូចនេះគឺជាការជាក់ស្តែងណាស់ ស្តេចសីហនុខ្លួនឯងបានរេរចូលអាមេរិកាំង ដោយអនុងយកសង្គ្រាមវៀតណាម (ឬអាមេរិកាំង-យួន) ទៅដុតបំផ្លាញអព្យាក្រឹត្យនៃប្រទេសកម្ពុជា តាំងពីឆ្នាំ១៩៦៧មកម្ល៉េះ... គឺមិនអាចជាទង្វើរបស់លន់-នល់បានទេ ។ ដូចនេះ បើយើងធ្វើការសាកល្បងវះកាត់ (autopsie) អំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិខ្មែរ ដែលសព្វថ្ងៃតុលាការអន្តរជាតិកំពុងតែអនុវត្តចោទប្រកាន់ទៅលើពួកមេដឹកនាំខ្មែរក្រហមនួន-ជា, អៀង-សារី និងខៀវសំផន យើងត្រូវតែរែកញែកត្រឡប់ក្រោយ សើរើប្រវត្តិសាស្ត្រខ្មែរតាំងតែពីឆ្នាំ១៩៦៧មកវិញ ។ គឺដោយហេតុថា សង្គ្រាមប្រល័យពូជសាសន៍ដែលបានរាតត្បាតប្រទេសកម្ពុជា បន្ទាប់ពីការទម្លាក់ស្តេចនៅថ្ងៃទី១៨មីនា១៩៧០ គឺបានចាប់ផ្តើមឡើងដោយជាក់ស្តែងទាន់ហន្តនៅឆ្នាំ១៩៦៧ នៅក្នុងពាក្យមួលបង្កាច់របស់ស្តេចសីហនុ ដែលចោទថាឧត្តមសេនីយ៍លន់-នល់ជាស៊ូហារតូខ្មែរ ថាបានបង្កើតព្រឹត្តិការណ៍ពិឃាតរង្គាលនៅសំឡូត ហើយបានរេរចូលអាមេរិកាំង ក្នុងគោលបំណងធ្វើការពិឃាតទ្រង់ ។ ការចោទបំភ័ន្តនេះ គឺជាអាវុធដ៏កាចសាហាវណាស់ ព្រោះវាអាចធ្វើឲ្យរលត់រលាយព្រះរាជាណាចក្រមួយបាន (ប្រទេសកម្ពុជា), ឬមហានគរមួយបាន (សហរដ្ឋអាមេរិក) ស្របតាមគម្ពីររបស់ជនជាតិយួន និងគម្ពីររបស់ជនជាតិយ្វីហ្វ (Juifs) ។

## <u>គម្ពីររបស់ជនជាតិយ្វីហ្វ (L'ecclésiastique)</u>

★★★ «វាមានរឿង៣យ៉ាងដែលធ្វើឲ្យខ្ញុំភ័យខ្លាចជាខ្លាំង ពាក្យមួលបង្កាច់មួយ ដែលឆ្លងកាត់ទីក្រុងពីចុងម្ខាងទៅចុងម្ខាង, ប្រជាពលរដ្ឋរើបរំជួលបះបោរ, នេះមួយ, ហើយនិងការចោទក្លែងបន្លំបំភ័ន្តមតិមហាជននេះ, មួយ, រឿងទាំងអស់នេះអាក្រក់ជាងសេចក្តីស្លាប់ទៅទៀត» ។

★★★ អំពីអណ្តាត

«សូមប្រយ័ត្នអំពីជននិយាយព្រោកប្រាជ្ញច្រើន និងជនទិលខូច, ជនបែបនេះបានធ្វើឲ្យមនុស្សច្រើនគ្នាណាស់ ដែលធ្លាប់រស់សុខសាន្តជាមួយគ្នា ត្រូវធ្លាក់រលាយខូចហិនហោច ។ អណ្ដាតទី៣បានធ្វើឲ្យប្រជាជនច្រើនគ្នារង្គោះរង្គើជាខ្លាំង, បានធ្វើឲ្យពួកអ្នកទាំងនេះខ្ចាត់ព្រាត់រាយប៉ាយ ពីប្រជាជាតិមួយទៅប្រជាជាតិមួយ ។ អណ្ដាតនេះបានបំផ្លាញមហានគរប្រកបដោយមហិទ្ធិឫទ្ធិជាច្រើន ព្រមទាំងបានផ្ដួលព្រលំវាំងរបស់មហាក្សត្រមួយចំនួនធំផងដែរ !

★★★ អំពើទុរយសពយ៉ាង (ក្នុងទំព័រសុភាសិត ៖ Les Proverbes)

វាមានរឿង៦យ៉ាងដែលព្រះយ៉ាហាវេ (យ៉ាវេហ) ស្អប់ខ្ពើមជាខ្លាំងណាស់...

«៧ដែលព្រលឹងរបស់ទ្រង់ចង់តែក្អួតចង្អោរគឺ ក្រសែភ្នែកមាក់ងាយ, អណ្ដាតកូតករ, ដៃដែលបង្ហូរឈាមរបស់ជនឥតទោស, ចិត្តថ្លើមដែលមានតែគោលបំណងអាក្រក់, ជើងដែលរត់បោលទៅធ្វើឃាតកម្ម, សាក្សីក្លែងក្លាយដែលគ្រលាស់តែអណ្ដាតកូតករ, ជនដែលបង្កបង្កើតជម្លោះរវាងបងប្អូនក្រុមគ្រួសារអ្នកដទៃ» ។

ដោយយោងតាមពន្លឺអត្ថបទសុភាសិតខាងលើនេះ គេអាចមើលឃើញយ៉ាងជាក់ច្បាស់ថា អ្នកនយោបាយជាន់ខ្ពស់បីរូប មានងារសុទ្ធសឹងតែសម្ដេចវាំង គឺជាអ្នកបង្កបង្កើតជម្លោះរវាងជនជាតិខ្មែរហើយនិងជនជាតិខ្មែរ, បង្កើតជម្លោះរវាងរាស្ត្រហើយនិងស្ដេច, រវាងមន្ត្រីហើយនិងមន្ត្រី ដោយសារមន្តអាគមនៃអណ្ដាតកូតករ ពោលគឺជាជនអធិករណ៍បង្កើតសង្គ្រាមប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា, គឺជាជនជាតិយួនហើយនិងជនជាតិយ្វីហ្វ ដែលបង្កប់ខ្លួននៅក្នុងរាជវាំងខ្មែរនេះឯង គឺសឹន-សាន, ញ៉ឹក-ជូឡុង និង ប៉ែន-នុត ។

ស្ដេចសីហនុជាស្ដេចខ្មែរ តែទ្រង់បានចំណេញអ្វីទៅ ក្នុងការប្រល័យពូជសាសន៍នៃជនជាតិកម្ពុជា ហើយនិងជុតបំផ្លាញនគរខ្លួនឯង ?? ចំណុចត្រង់នេះ ពាក្យចម្លើយដ៏សំខាន់មួយរបស់លោកនួន-ជា អាចយកមកបំភ្លឺមតិសាធារណជនបាន ៖ «អ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិខ្មែរ មិនមែនជាខ្មែរទេ គឺពួកជនបរទេស (លោកនួន-ជាបានបញ្ជាក់បន្ថែមទៀតថា គឺឡេយីង ហើយនិងគីស្សីងគ្គ័រ ពោលគឺជនជាតិយួន ហើយនិងជនជាតិយ្វីហ្វ!) ។

★★★ ពាក្យចម្លើយដ៏សំខាន់មួយទៀតរបស់មេខ្មែរក្រហមខៀវ-សំផន ក៏អាចយកមកធ្វើជាគោលបំភ្លឺអាថ៌កំបាំងនៅក្នុងបទប្រល័យពូជសាសន៍នេះដែរ គឺ «ពេលទឹកល្អក់ គេមិនអាចមើលឃើញសត្វត្រីទេ, ប៉ុន្តែនៅពេលទឹករងថ្លា គេអាចមើលឃើញអ្វីៗទាំងអស់ដែលលាក់កំបាំង» ។ ពេលនេះជាពេលទឹករងថ្លា ម៉្លោះហើយយើងអាចមើលឃើញដៃឃាតករទាំងអស់ដែលបានសម្លាប់ប្រជាជនខ្មែរបំផុតពូជក្នុងប្រការបំរើផលប្រយោជន៍ប្រជាជាតិយួន ៖

ទី១- សឺន-សាន, ជាចារបុរសកំពូលនៃវៀតណាមខាងជើង ដែលចូលមកបង្កប់ខ្លួនក្នុងរាជវាំងខ្មែរ ជាគ្រូឧបជ្ឈាយ៍របស់ស្តេចសីហនុ ។ សឺន-សាន ឬ សឺង-សាន ជាឈ្មោះចិន មានន័យថា ភ្នំថៃសាន ដែលជាភ្នំខ្ពស់ជាងគេបង្អស់នៅប្រទេសចិន ។ សឺន-សានមិនមានដើមកំណើតនៅប្រទេសខ្មែរផងទេ ហើយក៏ពុំមានកំណើតនៅកម្ពុជាក្រោមនោះដែរ ។ គាត់ជាជនជាតិយួនខាងជើង ដែលហូជីមិញបានប្រើឲ្យចូលមកប្រទេសកម្ពុជា ដើម្បីបំបែកបំបាក់ពូជពង្សស្តេចខ្មែរឲ្យប្រកាប់ប្រចាក់គ្នាឯងជាសង្គ្រាមស៊ីវិល ជាពិសេសបំបែកស្តេចសីហនុជាមួយនឹងម្តាយរបស់ខ្លួនឯង, ប្រហែលគ្នានឹងទ្រឿង-មិញយ៉ាំងក្នុងរជ្ជកាលព្រះម្ចាស់ក្សត្រីអង្គម៉ីក្នុងសតវត្សរ៍ទី១៩ ដែលបានប្រើជនយួនម្នាក់បន្ទំធ្វើជាខ្មែរ ដាក់ឈ្មោះថា «ភគវ៉ា» ឲ្យចូលមកខេត្តបាត់ដំបង ដើម្បីបំបែកបំបាក់សាមគ្គីភាព ដែលមកទល់ពេលនោះមានសភាពរឹងមាំឥតរង្គោះរង្គើ រវាងបងប្អូនស្តេចពីរនាក់ឈ្មោះអង្គអែម និងអង្គដួង ។ នៅក្នុងឆ្នាំ១៩៣២, នៅពេលដែលប្រទេសកម្ពុជាមិនទាន់មានអនុវិទ្យាល័យផង សឺន-សានបានទទួលសញ្ញាប័ត្រកំពូលកពនៅប្រទេសបារាំងរួចទៅហើយ «Diplome des Hautes Etudes Commerciales» ។ ប៉ុន្តែសឺន-សានបែរជាសំរេចមកធ្វើការនៅប្រទេសកម្ពុជាទៅវិញ ។ គាត់ចូលមកក្នុងខេត្តបាត់ដំបងនៅក្នុងឆ្នាំ១៩៣៦ បន្លំធ្វើជាខ្មែរក្រោម ហើយមករៀនភាសាខ្មែរនិងទំនៀមទំលាប់ខ្មែរ នៅក្រោមដំបូលផ្ទះរបស់ជីតារបស់ខ្ញុំខាងឪពុកឈ្មោះ លោកតាម៉ម-សុទ្ធ...។ ឪពុករបស់ខ្ញុំ, លោកសុទ្ធ-កូម៉េត បាននិយាយច្រើនដងណាស់ប្រាប់ខ្ញុំយ៉ាងតិចក៏១០០ដងដែរ អំពីអត្តចារឹករបស់លោកសឺន-សានថា «គាត់នេះមានឫកពារគួរសមហួសហេតុពេកណាស់... មិនអាចជាមនុស្សសុចរិតបានទេ» (Il est trop poli pour être honnête !) ។

ដូចនេះ, នៅក្រោមក្រសែភ្នែកនៃសាធារណជនខ្មែរ សឺន-សានបានសំដែងតួជា «មន្ត្រីទុចរិត» ។ នេះជាមធ្យោបាយដ៏ឆ្នើមរបស់គាត់ ដើម្បីលាក់បំបាំង «សួនតួ» ដ៏ពិតប្រាកដរបស់គាត់ ជាស្តេចព្រាយអសុរកាយនៅក្នុងពិភពងងឹត (Le Prince des ténèbres), ជាជនចារកិច្ចដ៏កំពូលរបស់វៀតណាមខាងជើង ។

២- ប៉ែន-នុត, ជាចៅរបស់ឧកញ៉ាប៉ែន ដែលមានដើមកំណើតជាជនពរទុយគ្គេ (យ្វីហ្វ) កាន់សាសនាកាតូលិក ហើយដែលជាមន្ត្រីក្នុងវាំងមហាក្សត្រខ្មែរអង្គដួង ។ អ្នកកាន់សាសនាកាតូលិក សុទ្ធសឹងជាជនជាតិយួន ។ ឧកញ៉ាប៉ែន ជាកូនចៅរបស់សម្តេចសង្ឃកាតូលិកបារាំង Monseigneur Miche ដែលជាមេក្លោងរបស់ជនជាតិយួនកាតូលិកនៅប្រទេសកម្ពុជា ។ ថ្ងៃមួយព្រះបាទអង្គដួងពឹងសម្តេចមីស្ហ ឲ្យសរសេរលិខិតមួយទៅព្រះចៅបារាំង Napoléon III ដើម្បីឲ្យជួយគាំពារ

ប្រទេសកម្ពុជា ប្រឆាំងនឹងការរាតទឹកដីរបស់យួន, បើពុំនោះសោតទេ គទៅអនាគតជនជាតិយួននឹងលេបត្របាក់ទឹកដីខ្មែរគ្មានសល់អ្វីឡើយ ។ ព្រះបាទអង្គដួងក៏ប្រើឧកញ៉ាប៉ែន និងឧកញ៉ាកុយនាំសារលិខិតនេះ ព្រមទាំងសួយសារអាករផងទៅថ្វាយស្តេចបារាំងណាប៉ូឡេអុងទី៣ ។ ប៉ុន្តែឧកញ៉ាប៉ែននេះបានលួចទម្លាយបេសកកម្មសម្ងាត់ខាងលើឲ្យខូចខ្លាយ រហូតដល់ស្តេចសៀមដឹង ដែលជាហេតុបណ្តាលឲ្យបេសកកម្មជាន់ខ្ពស់ខាងលើនេះ ក្លាយទៅជាមោឃៈអាសារឥតការ ។ ពីព្រោះស្តេចសៀមកាលនោះជាអាណាព្យាបាលរបស់ស្តេចខ្មែរ, ខេត្តខាងលិច និងខាងជើង បានត្រូវសៀមលេបត្របាក់ចង់អស់ទៅហើយ មានបាត់ដំបង, ស៊ីសុផុន និងសៀមរាប-អង្គរ ។ ម៉្លោះហើយស្តេចសៀមមានការពិរោធខ្ញាំងណាស់នឹងស្តេចខ្មែរ ដែលហ៊ានសាកល្បងទាក់ទងជាមួយស្តេចបារាំង...។ ដូចនេះសម្តេចប៉ែន-នុតជាចៅលួតរបស់ឧកញ៉ាប៉ែននេះឯង ដែលជាជនក្បត់ប្រយោជន៍ព្រះមហាក្សត្រខ្មែរ និងទឹកដីមាតុភូមិខ្មែរកាលក្នុងសតវត្សរ៍មុន !

៣- ញ៉ឹក-ជូឡុង, យោងតាមឯកសារ «Essai sur la démocratie au Cambodge», របស់ Philippe Preschez, ញ៉ឹក-ជូឡុងជាកូនមន្ត្រីយួនម្នាក់ ដែលបារាំងយកមកតែងតាំងជាចៅហ្វាយខេត្តនៅប្រទេសកម្ពុជា ។ ដូចនេះ ស្របនឹងពាក្យដែលពួកខ្មែរក្រហមបានពោល ញ៉ឹង-ជូឡុងជាជន«ក្បាលយួនខ្លួនខ្មែរ» សុទ្ធសាធ ។

ទោះជាយ៉ាងណាក្តី សម្តេចរាំងបីរូបជំទួងខ្ពស់ជាងគេក្នុងរជ្ជកាលសីហនុ ក៏ដូចជាសម្តេចរាំងបីនាក់ក្នុងរជ្ជកាលម្ចាស់ក្សត្រីអង្គម៉ីជែរ (១- ត្រឿង-មិញយ៉ាំង, ២- ត្រាំង-យ៉ាំងណាង, ៣- ផាំ-យ៉ាំងឌៀន) គឺសុទ្ធសឹងជាជនដែលបំរើផលប្រយោជន៍វៀតណាម ហើយដែលគោលបំណងដ៏មុតមាំ ឬឧត្តមគតិដ៏ថ្លៃថ្លាបំផុត គឺការបំផ្លិចបំផ្លាញព្រះមហាក្សត្រខ្មែរ និងជនជាតិខ្មែរ ។

៤- ចៅ-សេង - នៅក្នុងឆ្នាំ១៩៦៤ សម្តេចសីហនុមានការព្រួយបារម្ភជាខ្លាំង ខ្លាចក្រែងពួកសេអ៊ីអាអាមេរិកាំងមកពិឃាតទ្រង់ ដូចពួកគេបានពិឃាតង៉ោ-ឌិមយៀមនៅព្រៃនគរ ។ សម្តេចក៏បានថ្លែងប្រកាសជាឧឡារិកតាមវិទ្យុជាតិថា ក្នុងលក្ខណៈណាដែលទ្រង់ត្រូវបាត់បង់រូបភ្លាមមួយរំពេច សូមឲ្យប្រជាពលរដ្ឋខ្មែរទទួលយកព្រះអង្គម្ចាស់នរោត្តម-នរទីប៉ោ (រាជបុត្រមួយអង្គរបស់ទ្រង់) ជាអ្នកស្នងរាជ្យ ដោយមានទីប្រឹក្សា៤នាក់គឺ «សម្តេចចក្រីញ៉ឹក-ជូឡុង, សម្តេចបវរសេដ្ឋាសឺន-សាន, សម្តេចចៅហ្វាប៉ែន-នុត ហើយនិងឯកឧត្តមចៅ-សេង» ។

ឧត្តមសេនីយ៍លន់-នល់ មេទ័ពស្មោះត្រង់ជាមួយនឹងរាជបល្ល័ង្កជាយូរណាស់មកហើយ ឥតមាននៅក្នុងឧត្តមក្រុមប្រឹក្សារបស់នរទីប៉ោនោះទេ ។ ដូចនេះយើ

ងអាចសម្លឹងមើលឃើញដោយត្រឹក្បាលថា ពួកមន្ត្រីដែលនៅរួមរិតស្ដេចសីហនុទាំងប៉ុន្មាន សុទ្ធសឹងតែជាជនក្បត់ គឺពីព្រោះថា វាមិនអាចមានបី ហើយអត់បួន ! ពួកនេះសឹងតែពិឃាតស្ដេច ដោយចាក់នឹងកាំបិតក៏បានដែរ ។

នៅក្នុងឆ្នាំ១៩៦៧ លោកចៅ-សេងបានចោទលោកស៊ឹម-វ៉ារថា ជាមេភ្នាក់ងាររបស់សេអ៊ីអា (ដោយភ្ជាប់រូបខ្ញុំផង ដែលជាក្មួយលោកស៊ឹម-វ៉ារថា ជាភ្នាក់ងារសេអ៊ីអាម្នាក់ដែរ)ព្រមទាំងញុះញង់ស្ដេចថា លោកលន់-នល់ជាស៊ូហារតូ, តាមពិតចៅ-សេងខ្លួនឯងជាជនក្បត់ស្ដេចទៅវិញសោះ ! ក្បត់នោះ គឺក្បត់ទាំងក្រុមទាំងចង្កោមតែម្ដង ។ ចៅ-សេងនេះហើយជាមេក្រុមម៉ៅនិយម ដែលបានណែនាំជា-សាន, ផូ-បូពិន, ចាន់-យូរ៉ាន់, ហួត-សម្បត្តិ, សារិន-ឆាក... ឲ្យហែរហមស្ដេចសីហនុ តាមក្រោយគន្ធងធមិរបស់សម្ដេចប៉ែន-នុត... ទៅបង្កើតរដ្ឋាភិបាលខ្មែរក្រហមនៅប៉េកាំង (នៅឆ្នាំ១៩៧០) ដើម្បីធ្វើចំបាំងវាំងជល់ប្រហារពួកទីក្រុងភ្នំពេញ ទាល់តែរលត់រលាយនគរកម្ពុជា !! សភាពការណ៍ដែលគួរឲ្យអស្ចារ្យ គឺពួកក្រុមឆ្វេងហើយនិងក្រុមស្ដាំត្រូវរ៉ូវតែគ្នា, ពួកប្រូអាមេរិកាំង (ញឹក-ជូឡុង, សឺន-សាន) និងពួកប្រូចិន (ប៉ែន-នុត, ចៅ-សេង) ...តាមពិតទៅ គឺជាក្រុមតែមួយ ។ គោលជំហររបស់ពួកគេក៏មានតែមួយ គឺយកប្រទេសកម្ពុជាទៅប្រគល់ឲ្យជនជាតិយួន ។

★★★ បន្ទាប់ពីមានបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅសំឡូត (ដែលជាស្នាដៃរបស់សឺន-សាន ហើយនិងញឹក-ជូឡុង)... ប៉ុន្តែអ្នកផងបានទម្លាក់កំហុសទៅលើលោកលន់-នល់ (លោកឃឹម-ទិត ដែលជាជនស្ដាំនិយម បានទាំងចោទមូលបង្កាច់តាមវេទិកានៃអង្គការសហប្រជាជាតិថា «លោកលន់-នល់បានសម្លាប់ខៀវ-សំផន, ហ៊ូ-យន់, ហ៊ូ-នឹម ដោយចាក់សាំងដុតទាំងរស់» (sic!)... លោកចៅ-សេង ជាមួយនិងស្ថានទូតចិន និងជាមួយមេកន្ទ្រាញចិនម៉ៅនិយមម្នាក់ឈ្មោះ ចៅ-ខុង (ជាចៅកែសាលារៀនចិននៅភ្នំពេញ ជាមេក្លោបក្លាប់សេដ្ឋកិច្ចនៃប្រទេសកម្ពុជាទាំងមូលចង់ធ្វើឲ្យភ្លៀងៗ-ផ្គរៗ, និងជាអ្នកផ្គត់ផ្គង់ស្រីញី, អាភៀននិងលុយកាក់តាមចំណង់ជល់សម្ដេចប៉ែន-នុត)... លោកចៅ-សេងក៏ចាប់ផ្ដើមវាយប្រហារទៅលើស្ដេចសីហនុ ថាជាជនសក្តិភូមិ-ប្រតិកិរិយា...។

★★★ នៅក្នុងសារទូរលេខមួយ ដែលក្រុមអាជ្ញាធរនៅប៉េកាំងបានផ្ញើមកសមាគមចិន-ខ្មែរនៅភ្នំពេញ, ហើយដែលមានមេខ្មែរក្រហមភោគ-ឆាយជាប្រធាន, នៅថ្ងៃទី៩កញ្ញា១៩៦៧, មានចោទប្រកាន់បញ្ជិតបញ្ចៀងថា «ពួកប្រតិកិរិយា» ( Réaction» ៖ សីហនុ+លន់នល់) ជាអ្នកធ្វើការបង្ក្រាបព្រៃផ្សៃទៅលើប្រជាជននៅសំឡូត ។ ចៅ-សេងបានយកអត្ថបទសារទូរលេខនេះ មកចុះផ្សាយក្នុងទំព័រទី២

*នៃសារពត៌មានរបស់ខ្លួន «La Nouvelle Dépêche du Cambodge» ជាហេតុឲ្យស្តេចសីហនុមានសេចក្តីក្រេវក្រោធពិរោធពន់ប្រមាណ, បិទសារពត៌មានទាំងអស់នៅភ្នំពេញ មានសារពត៌មានខ្មែរ, បារាំង, ចិន...។ ចៅ-សេងខ្លួនឯងមានកាតព្វកិច្ចភៀសខ្លួនទៅប្រទេសបារាំង...។*

*★★★ ព្រឹត្តិការណ៍ក្រោយនេះគ្រាន់តែបានបង្ហាញឲ្យឃើញថា ប្រទេសចិនក៏បានលូកដៃទម្លាក់ស្តេចសីហនុផងដែរនៅឆ្នាំ១៩៦៧... ដូច្នេះគឺមានឈាមប្រឡាក់ដៃនៅក្នុងបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៃជនជាតិខ្មែរនៅសំឡូត ។ ប៉ុន្តែទង្វើនេះ ពុំមែនជាទង្វើរបស់រដ្ឋាភិបាលចិនទេ... ថ្ងៃក្រោយមក, លោកជូ-អេនឡាយបានបញ្ជាក់ប្រាប់ស្តេចសីហនុថា (មានចុះផ្សាយនៅក្នុង My war with the CIA)... រដ្ឋាភិបាលចិនមិនបានគាំទ្រពួកចិនម៉ៅនិយមដែលប្រឆាំងនឹងរាជរដ្ឋាភិបាលខ្មែរនៅសម័យ១៩៦៧នោះទេ ។ គឺជាទង្វើរបស់សេនាប្រមុខលិន-ពាវ ជនជំនិតទី២របស់លោកប្រធានម៉ៅនៅក្នុងបក្សកុម្មុយនិស្តចិន ដែលជាមេពួកឆ្មាំក្រហមនៅប៉េកាំង ។ (លិន-ពាវនេះជាចិនម៉ុងគោ្គល, ជាជនក្បត់លោកប្រធានម៉ៅ ជា«ក្បាលយួនខ្លួនចិន»... យួន-សៀម-យ្ហីហ្វ និងម៉ុងគោ្គល មានឫសគល់តែមួយ) ។ តាមសំណេររបស់ស្តេចសីហនុផ្សាយចេញពីប៉េកាំងតាម Internet, មាននិយាយថា នៅថ្ងៃទី១៥សកា១៩៧០, គឺថ្ងៃដែលប្រធានម៉ៅបានសំរេចជួយស្តេចសីហនុឲ្យបង្កើតរដ្ឋាភិបាលខ្មែររំដោះ... លិន-ពាវផឹកស្រាស្រវឹងអួរទីទួរ ជុំក្ងិន៥ម៉ែត្រ ហើយនិយាយឥតដឹងអីទេ... ទំនងជាភ័យខ្លាចថាម៉ៅ-សេទុងចាប់ថ្នាក់បានថាខ្លួនជាជនក្បត់ក៏មិនដឹងដែរ ។ នៅក្នុងឆ្នាំ១៩៧១ លិន-ពាវមានគំរោងការសម្លាប់លោកប្រធានម៉ៅលែងបង្អែបង្អង់, ប៉ុន្តែការប្រាថ្នានេះមិនបានចេញរូបរាង, ពីព្រោះកូនស្រីលិន-ពាវខ្លួនឯង ដែលជាកូនឆ្មាំក្រហមម្នាក់ បានទៅធ្វើសេចក្តីរាយការណ៍អំពីគំរោងក្បត់របស់ឪពុកខ្លួនប្រាប់រដ្ឋាភិបាលចិនគ្មានសល់ ។ លិន-ពាវហើយនិងប្រពន្ធ ហើយនិងកូនប្រុសដែលមានឈ្មោះថា អាបេ-៥២ កូនប្រុសនេះជាអាកាសយានិកយោធា ដែលមានភារកិច្ចយកគ្រាប់បែកទៅទម្លាក់លើលោកប្រធានម៉ៅ, ក៏លួចយកយន្តហោះចិនមួយ ហោះហើរទៅធ្លាក់ស្លាប់នៅក្នុងដែនដីម៉ុងគោ្គលបាត់ (សូមអានឯកសារចិនមួយមានចំណងជើងថា MAO, មានលក់នៅគ្រប់ទីកន្លែងនៅក្នុងសហរដ្ឋ, នៅក្នុងនោះមានរូបថតចុងក្រោយរបស់លិន-ពាវជាមួយម៉ៅ-សេទុង, ជាមួយនឹងសម្តេចសីហនុ ហើយនិងអ្នកម្នាងម៉ូនិក...។ លិន-ពាវចូលមកជួបម៉ៅ-សេទុងចំនួន១៥នាទី, មិននិយាយរកអ្នកណាទាំងអស់ សូម្បីតែស្តេចសីហនុហើយនិងអ្នកម្នាងម៉ូនិក ក៏លិន-ពាវមិនខ្ចីនិយាយរកផង ។ រួចហើយលិន-ពាវក៏ដើរចេញទៅបាត់ តម្រង់ទៅរកសេចក្តីស្លាប់) ។*

ទី៥- Charles Meyer

លោក Charles Meyer នេះជាយ៉ីហ្វ តាំងពីក្បាលដល់ចុងជើង ជា«ជនក្បាលយួនខ្លួនបារាំង»...។ គាត់មិនមានមុខតំណែងធំដុំប៉ុន្មានទេនៅកម្ពុជា, គ្រាន់តែជាអ្នកនិពន្ធម្នាក់ ដែលជួយសរសេរអត្ថបទបារាំងថ្វាយសម្តេចសីហនុតែប៉ុណ្ណោះ ។ ប៉ុន្តែគាត់មានឥទ្ធិពលខ្លាំងណាស់ ទៅលើនយោបាយឆ្វេងនិយមរបស់ស្តេចសីហនុ, គាត់នេះហើយជាស្ថាបត្យករដ៏ចំណានប្រកបដោយទេពកោសល្យខ្ពង់ខ្ពស់អស្ចារ្យខាងរៀបចំទំនាក់ទំនងរអួករអឺន រវាងស្តេចសីហនុហើយនិងពួកមេដឹកនាំកុម្មុយនិស្តអាស៊ីទាំងអស់ (ទាំងនេះគឺជាសេចក្តីដែល Bernard Hamel, បារាំងស្តាំនិយម្នាក់បានប្រាប់ខ្ញុំដោយផ្ទាល់) ។

ប៉ុន្តែលោក David Chandler ប្រវត្តិវិទូដ៏ល្បីល្បាញម្នាក់បានប្រាប់ខ្ញុំថា លោក Charles Meyer នេះជាភ្នាក់ងាររបស់រដ្ឋាភិបាលបារាំង («Un agent du Gouvernement français») ។ ដូចនេះ ស្របតាមពាក្យលោកខៀវ-សំផនបញ្ជាក់, ទឹកកាន់តែរងថ្លា យើងកាន់តែមើលឃើញច្បាស់... ក្បាលនរណាសក់អ្នកនោះ ដៃនរណាសម្លាប់មនុស្ស អ្នកនោះឯងជាឃាតករ ។ លោក Charles Meyer ជាដៃរបស់រដ្ឋាភិបាល Pompidou, ដូចនេះ កាលណាលោក Charles Meyer ចាប់ផ្តើមវាយប្រហារទៅលើស្តេចសីហនុ, គឺរដ្ឋាភិបាលបារាំងរបស់លោក Georges Pompidou នោះឯង ជាអ្នកអ្នកចាក់សម្លាប់ពីក្រោយខ្នង រុញច្រានស្តេចសីហនុឲ្យធ្លាក់ទឹក, ព្រមទាំងយកភ្លើងសង្គ្រាមទៅបង្កាត់ដុតប្រទេសកម្ពុជា, ស្របពេលជាមួយគ្នានឹងអាមេរិកាំង-យួន ។ ដូចនេះគឺរដ្ឋាភិបាលបារាំងនេះឯង ដែលគួរតែយកមកកាត់ទោសអំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅតុលាការខ្មែរក្រហមបច្ចុប្បន្ន ។

សូមអានអត្ថបទដកស្រង់ពីសៀវភៅរបស់លោក Milton Osborne, «Sihanouk... Prince of light, prince of Darkness», ត្រង់ចំណុច Charles Meyer - (P-175) ៖

«បន្ទាប់ពីបានដើរតួជាយូរឆ្នាំជាអ្នកនាំពាក្យរបស់សម្តេច និងនយោបាយរបស់ទ្រង់, Meyer ស្រាប់តែប្រែក្លាយទៅជាអ្នកតិះទៀនធ្ងន់ធ្ងរទៅលើចៅហ្វាយរបស់ខ្លួន... (សីហនុ) ។ នៅល្ងាចថ្ងៃមួយ (១៩៦៧) ពេលផឹកស៊ីមួយជាមួយមិត្តភក្តិមួយក្រុម, Meyer បានថ្លែងថា សីហនុកំពុងតែបង្ហាញជម្ងឺឆ្កួតលីលា ធ្លងមកពីស្តេចជីតារបស់ខ្លួន គឺស្តេចនរោត្តម ។ ស្តេចល្អិតនេះពុំអាចយកជាការអ្វីបានទៀតទេ គឺកំពុងវិលត្រឡប់ទៅសម័យដើមវិញ ដែលទ្រង់ចូលចិត្តជិះសេះ និងដើរតួកុន»..

(នៅមានត)

អន្តរប្រិយ
សម្លេងខ្មែរនៅបរទេស

# កាលប្បវត្តិវិទ្យានៃសង្គ្រាមប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា (ភាគ២)

## Chronologie du génocide cambodgien (2ème partie)

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី២០ មិថុនា ២០០៨

★★★ តទៅនេះគឺជាអត្ថបទរបស់ខ្ញុំផ្ទាល់ដកស្រង់ពី «Le Chemin de l'Apocalypse»... គឺជាសេចក្តីសន្ទនារបស់ខ្ញុំជាមួយឪពុកធំ ស៊ុម-រ៉ាវ នៅចុងខែសីហា ១៩៦៩, បន្ទាប់ពីមានការតែងតាំងរដ្ឋាភិបាល «ស្រោចស្រង់ជាតិ លន់នល់-សិរិមត:» ៖

– «តើលោកអ៊ុំអាចដឹងបានទេ អំពីយោបល់របស់ Charles Meyer ទៅលើសម្តេចសីហនុពេលនេះ ?

– Charles Meyer ក៏មានសេចក្តីរំពឹងទៅលើទ្រង់ស៊ីសុវត្ថិ-សិរិមត: ថាជាវរជនជំនួស ឬបន្ទាស់ផងដែរ ។ ចំពោះសម្តេចសីហនុ, Charles Meyer បានយល់ថា ជាស្តេចអស់ផ្លូវកែហើយ... ស្តេចនេះបានបន្ទោកបន្ទាបខ្លួនឯងរហូតដល់ថ្នាក់មួយងើបមុខឡើងវិញលែងរួច ។ Charles Meyer បាននិយាយបន្ថែមថា សូម្បីតែស្ថានទូតចិនក៏មានការពេបជ្រាយទៅលើស្តេចសីហនុផងដែរ ដែលចូលចិត្តសប្បាយ ហើយលែងរវីរវល់នឹងកិច្ចការរដ្ឋ ។ កាលពីដើមពិតមែន គឺជាស្តេចមានប្រជាប្រិយភាព, ប៉ុន្តែ... ពួកចិនទុកស្តេចសីហនុឥឡូវប្រហែលគ្នានឹងសំរាម...»។

★★★ ត្រង់កន្លែងនេះ យើងគួរសង្កេតឃើញថា, Charles Meyer, បារាំងម្នាក់ម៉ៅនិយម ដែលស្អប់អាមេរិកាំងដល់ឆ្អឹង បែរទៅជាឃុបឃិតគ្នាជាមួយនឹង Bernard Hamel នៅឆ្នាំ១៩៦៩, គាំទ្រទ្រង់សិរិមត: មេក្លោងក្រុមនយោបាយស្តាំនិយមខ្មែរប្រូអាមេរិកាំង ដើម្បីទម្លាក់ស្តេចក្រហមសីហនុ ដែលប្រូចិនទៅវិញ ??

គិតទៅបារាំងច្រើនបារាំងស្តាំទាំងប៉ុន្មាននៅកម្ពុជា គឺសុទ្ធសឹងជាបារាំងឃ្វីហ្គ្មានឧត្តមគតិអ្វីទេ ក្រៅពីការក្បត់ស្តេចខ្មែរ និងក្បត់លោកប្រធានាធិបតីបារាំង Charles De Gaulle ដែលជាអ្នកគាំពារប្រទេសកម្ពុជា មិនឲ្យធ្លាក់ទៅក្នុងភ្លើងសង្គ្រាម ។

*ជនយ៉ូហ្វទាំងអស់ខាងលើនេះ (ពួក«ក្បាលយួនខ្លួនខ្មែរ», «ក្បាលយួនខ្លួនចិន», «ក្បាលយួនខ្លួនបារាំង»)...សុទ្ធសឹងតែជាពួកបញ្ចើក្អែក, ពួកធ្មិនក្បាលស៊ីក្បាល ធ្មិនកន្ទុយស៊ីកន្ទុយ, ស៊ីត្រង់ណាជុះត្រង់ហ្នឹង, ទៅបំរើប្រទេសណា គឺត្រូវបំផ្លាញប្រទេសហ្នឹង ដូចកណ្ដៀរស៊ីសសរផ្ទះ ឬដូចច្រែសដែលកើតមកពីដែក ហើយស៊ីដែកទៅវិញ !!*

*★★★ លោក Georges Pompidou, រដ្ឋមន្ត្រីទី១បារាំងសម័យនោះក៏ជាជនយ៉ូហ្វ ដែលបំរើស្ដេចយ៉ូហ្វបារាំង Rottschild, ហើយក្បត់លោកដឺគ្គោល... ដូចតែនៅសហរដ្ឋអាមេរិក លោកគីស្សីងគ្គើរ ជនយ៉ូហ្វដែលបំរើស្ដេចយ៉ូហ្វអាមេរិកាំង Rockfeller (ស្ដេចប្រេងកាត) ហើយក្បត់លោកប្រធានាធិបតីនិចសុនដូចនោះដែរ ។ នៅឆ្នាំ១៩៦៩, លោកប៉ុមពីឌូ បានធ្វើនយោបាយខ្ទាស់ជើងលោកឌឺគ្គោល បណ្ដាលឲ្យគាត់ដើរចេញពីអំណាច; ដូចនៅក្នុងឆ្នាំ១៩៧០, ទ្រង់សិរិមតៈ (ជនយួនកាត់សៀម) បានខ្ទាស់ជើងសីហនុ បណ្ដាលឲ្យព្រះអង្គរត់ចោលស្រុក; ដូចនៅក្នុងឆ្នាំ១៩៧៤, គីស្សីងគ្គើរបានបង្កើតរឿងវិបត្តិ Watergate ខ្ទាស់ជើងលោកនិចសុន បណ្ដាលឲ្យលោកប្រធានាធិបតីអាមេរិកាំងប៉ើងខ្ទាតចេញពីតំណែង ។ ជនយ៉ូហ្វគឺជនក្បត់, «ជនយូដា»សម្លាប់ព្រះ (ព្រះយេស៊ូ) ជាជនដណ្ដើមអំណាចធ្វើរដ្ឋប្រហារទម្លាក់ (ឬពិឃាត) លោកប្រធានាធិបតី... ឬទម្លាក់ (ឬពិឃាត) ស្ដេច !!*

❑ ❑ ❑

*<u>មករា ១៩៦៨</u> ៖ រដ្ឋមន្ត្រីទី១ សឺន-សាន នៅទីក្រុងភ្នំពេញបានធ្វើការចរចាជាមួយ Chester Bowles (អគ្គរដ្ឋទូតអាមេរិកាំងប្រចាំប្រទេសឥណ្ឌា) ដើម្បីស្វែងរកមូលដ្ឋានភ្ជាប់ចំណងទូតឡើងវិញរវាងប្រទេសកម្ពុជានិងស.រ.អា ។ នៅក្នុងការចរចានេះ ភាគីអាមេរិកាំងយល់ព្រមទទួលស្គាល់បូរណភាពទឹកដីខ្មែរ, ចំណែកខាងភាគីកម្ពុជាវិញ សុខចិត្តយល់ព្រមឲ្យទ័ពអាមេរិកាំង ដេញតាមវាយប្រហារយៀកកុងក្នុងទឹកដីខ្មែរ ក្នុងលក្ខណៈណាជាប់ដៃគ្នាប្រផាប់ប្រភីង !!*

*ដូចនេះ យើងគួរសង្កេតឃើញថា សឺន-សានបានអនុញ្ញាតឲ្យអាមេរិកាំងទទួលស្គាល់បូរណភាពទឹកដីខ្មែរផង ហើយឲ្យបំពានក្នុងពេលជាមួយគ្នាផង ។ គឺដូចជាស្រីសំផឹងម្នាក់ដែលបើកសំពត់ឲ្យគេ នៅគ្រាជួបគ្នាដំបូង ។ នេះគឺជាការបង្ហាត់ភ្លើងរបស់មេធ្មប់សឺន-សាន ដើម្បីដុតប្រទេសកម្ពុជាឲ្យក្លាយទៅជាផេះ ពីព្រោះដៃម្ខាងគាត់ដឹកស្បៀង គ្រឿងអាវុធ ហើយនិងក្រដាស់ប្រាក់រៀលទាំងតោនយកទៅបំពោកឲ្យយៀកកុង (ក្នុងទឹកដីខ្មែរ), ហើយដៃម្ខាងទៀត គាត់ប្រទាញកងទ័ពអាមេរិកាំង-យួនខាងត្បូង ឲ្យធ្វើការលុកលុយមាតុភូមិខ្មែរ ។ រួចហើយគាត់លួចថយខ្លួន ទៅពួននៅប្រទេសបារាំង ដោយលបចាំមើលលទ្ធផលនៃអំពើអាក្រក់*

របស់គាត់ ។ គាត់បានសរសេរសុំបុត្រមួយទៅស្តេចសីហនុថា ៖ «Je me permet de prendre ma retraite sur la pointe de mes pieds» («ទូលព្រះបង្គំសូមអនុញ្ញាតថយខ្លួនទៅចូលនិវត្តន៍ ដោយដើរជំរើតជើងលបៗ») ។

❑ ❑ ❑

<u>មេសា ១៩៦៨</u> ៖ សម្តេចសីហនុតែងតាំងសម្តេចប៉ែន-នុតឲ្យដឹកនាំ «រដ្ឋាភិបាលនៃក័ព្វសំណាងចុងក្រោយ» (Le Gouvernement de la dernière chance) ។ គួរកត់សម្គាល់ថា ប៉ែន-នុតគឺជាមេក្លោងក្រុមចិនក្រហម-បដិវត្តន៍វប្បធម៌ម៉ៅនិយមនៅភ្នំពេញ, គឺពួកក្រុមចៅ-ខុង... ប៉ុន្តែនៅក្នុងឆ្នាំ១៩៦៨ រដ្ឋាភិបាលប៉ែន-នុតបែរជាធ្វើការបង្ក្រាបដ៏កាចសាហាវអស្ចារ្យ ទៅលើបុគ្គលិកនៃក្រសួងសិក្សាធិការជាតិ ដោយបានបាញ់សម្លាប់ពួកគ្រូបង្រៀនពាសវាលពាសកាល ដោយចោទថា ពួកនេះជាពួកខ្មែរក្រហមទៅវិញ ។ ខ្លួនខ្ញុំបានឃើញផ្ទាល់នឹងភ្នែក ឃើញពួកប៉ូលិសសម្ងាត់របស់អ៊ុំ-ម៉ាណូរិន ដេញតាមបាញ់សម្លាប់គ្រូបង្រៀនម្នាក់នៅផ្សារសួនចាស់ (នៅខាងកើតវត្តមហាមន្ត្រី) ។ ស្ថាបត្យករនៃនៃការពិឃាតព្រៃផ្សៃនេះ គឺជាការចម្លែកណាស់ គឺលោកវណ្ណ-មូលីវណ្ណ, រដ្ឋមន្ត្រីក្រសួងសិក្សាធិការជាតិ, ក្មួយរបស់សម្តេចប៉ែន-នុត, ដែលអ្នកផងបានចាត់ទុកថាជាបញ្ញាជនខាងឆ្វេង (វណ្ណ-មូលីវណ្ណនេះជាក្រុមមិត្តភក្តិរបស់ Charles Meyer) ។ គឺវណ្ណ-មូលីវណ្ណនេះឯង ដែលបានប្រគល់បញ្ជីខ្មៅនៃពួកគ្រូបង្រៀនដែលត្រូវសម្លាប់ ទៅឲ្យមេប៉ូលីសឃាតករអ៊ុំ-ម៉ាណូរិន ។

អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ សូមអានអត្ថបទមួយដកស្រង់ពីសៀវភៅលោក Milton Osborne ដដែល (p-197) ៖

«នៅថ្ងៃ៥ ខែឧសភា ១៩៦៨, សីហនុបានអនុញ្ញាតឲ្យព្រឹត្តិប័ត្រទីភ្នាក់ងារពត៌មានខ្មែរ ចុះផ្សាយអំពីជោគជ័យរបស់ទ្រង់ ក្នុងប្រការបង្ក្រាបពួកជនបះបោរ (ពួកគ្រូបង្រៀន) ...ទ្រង់បានអួតថា ទ្រង់បានបញ្ជាឲ្យគេបាញ់ពួកនេះចោលអស់២០០នាក់ ដោយគ្មានជំនុំជំរះ នៅប៉ែកខាងជើងឆៀងខាងកើតនៃព្រះរាជាណាចក្រ ។ នេះពុំមែនជារឿងតែមួយទេ ដែលសីហនុធ្លាប់បានអួតអាងជាសាធារណៈ ។ យោងតាមប្រភពមួយរបស់ Ben Kiernan, គឺសីហនុអង្គឯង ដែលបានបញ្ជាឲ្យពិឃាតគ្រូបង្រៀន៤០នាក់ ដោយទម្លាក់ឲ្យពួកនេះឲ្យបាក់ឆ្អឹងស្លាប់ពីលើកំពូលភ្នំបូកគោ...» ។

★★★ ដូចនេះ «រដ្ឋាភិបាលនៃក័ព្វសំណាងចុងក្រោយ»របស់ប៉ែន-នុត គឺជារដ្ឋាភិបាលឃាតករ ដែលជង្គ្រែស្តេចសីហនុឲ្យសម្លាប់គ្រូបង្រៀន ។ អព្ភូតហេតុដ៏ជំអស្ចារ្យជាងនេះទៅទៀត គឺសម្តេចប៉ែន-នុតនេះឯងដដែល នៅក្នុងខែមីនា១៩-

៧០ ដែលជាអ្នកដង្ហែស្តេចសីហនុទៅទីក្រុងប៉េកាំង ទៅបង្កើតរដ្ឋាភិបាលឃាតករមួយទៀតគឺ រដ្ឋាភិបាលពួកគ្រូបង្រៀនខ្មែរក្រហម ឲ្យមកសម្លាប់ពួកទីក្រុងភ្នំពេញវិញម្តង ៖ គឺជាការច្បាស់ណាស់ ប៉ុល-ពត, អៀង-សារី, ខៀវ-សំផន, ខៀវ-ធីរិទ្ធ, ខៀវ-ប៉ុណ្ណារី, ហ៊ូ-យន់, ហ៊ូ-នឹម សុទ្ធសឹងជាពួកអតីតគ្រូបង្រៀន...

❑ ❑ ❑

<u>មករា ១៩៦៩</u> ៖ លោកប្រធានាធិបតីនិចសុន ចូលកាន់កាប់សេតវិមាន ។ ចំណាត់ការទី១របស់លោក គឺការប្រកាសដកកងទ័ពអាមេរិកាំងចេញពីវៀតណាម ហើយដំណើរទស្សនកិច្ចផ្លូវរដ្ឋទី១របស់លោក គឺធ្វើឆ្ពោះទៅប្រទេសបារាំងរបស់ឧត្តមសេនីយ៍ដឺគ្គោល ។ ម៉្លោះហើយគោលប្រាថ្នារបស់លោកនៅពេលនោះបានលេចឡើងច្បាស់ណាស់... លោកត្រូវការចរចាជាមួយប្រទេសចិន ដើម្បីបញ្ចប់សង្គ្រាមនៅវៀតណាម ។ លោកឧត្តមសេនីយ៍ដឺគ្គោលជារដ្ឋបុរសតែមួយនៅពិភពខាងលិច ដែលបានដាក់ចំណងទូតជាមួយប្រទេសចិន (តាំងពីឆ្នាំ១៩៦៦)... លោកនិចសុនត្រូវការយោបល់ពីប្រមុខរដ្ឋបារាំង ដែលលោកធ្លាប់ស្រឡាញ់និងគោរពតាំងពីសង្គ្រាមលោកលើកទី២អំពីប្រការនេះ ។

គួរកត់សម្គាល់ថា លោកឧត្តមសេនីយ៍ដឺគ្គោលនិងលោកប្រធានម៉ៅ ជាអ្នកដឹកនាំនៃរដ្ឋអំណាចពីរ ដែលទទួលស្គាល់និងធានាបូរណភាពទឹកដីនិងអព្យាក្រឹតភាពនៃប្រទេសកម្ពុជារបស់ស្តេចសីហនុ ។ តើលោកនិចសុនមានប្រយោជន៍អ្វីទៅ ក្នុងប្រការពន្លាតភ្លើងសង្គ្រាមវៀតណាម ចូលក្នុងមាតុភូមិខ្មែរនោះ ?? បានសេចក្តីថា ទង្វើទម្លាក់គ្រាប់បែបកនៅប្រទេសកម្ពុជា ដែលចាប់ផ្តើមនៅថ្ងៃទី១៨មីនា១៩៦៩ និងការទម្លាក់ស្តេចសីហនុនៅថ្ងៃទី១៨មីនា១៩៧០ មិនមែនជាទង្វើរបស់លោកទេ ។ គឺជាទង្វើរបស់ជនក្បត់ Henry Kissinger ទីប្រឹក្សាផ្នែកសន្តិសុខរបស់លោក ។

★★★ នៅក្នុងឆ្នាំ១៩៧២ នៅពេលដែលលោកនិចសុនចូលទៅជួបចាប់ដៃលោកប្រធានម៉ៅជាលើកដំបូង នៅក្នុងបន្ទប់បណ្ណាល័យរបស់លោក, លោកម៉ៅសេទុងបានសង្កេតដោយភ្នែកមុតរបស់លោក ថាគីស្សីងគ្គើរ ជាជនក្បត់របស់លោកនិចសុនស្រេចបាត់ទៅហើយ (ជាធម្មតាលោកម៉ៅ-សេទុងធ្លាប់បានកំចាត់សម្តេចកាំងដំឆ្នើម, លី-ចាវជី, ស្តាំនិយមជ្រុល... និងលិន-ពាវ ឆ្វេងនិយមជ្រុល ឲ្យបាត់ស្រមោលពីផែនដីលោក... ម៉្លោះហើយលោកស្គាល់ជនក្បត់ច្បាស់ណាស់ មិនអាចមើលច្រឡំទេ !) ។

លោកនិចសុនជាមេដឹកនាំមហាអំណាចដ៏ធំជាងគេក្នុងពិភពលោក ស្រាប់តែលោកចូលមកជួបលោកប្រធានម៉ៅ ដោយគ្មាននាំសហការីជាន់ខ្ពស់មកជាមួយ

សោះ ជាពិសេសលោករដ្ឋមន្ត្រីការបរទេស William Rogers, ប្រែជានាំមនុស្ស ឡែបឡប ឡេមឡឺមម្នាក់ (Kissinger) ដែលគ្មានឋានៈអ្វីធំដុំសោះ ក្រៅតែពីជនដណ្តើមអំណាច និងកាត់មុខមាត់លោកប្រធានាធិបតីខ្លួនឯង !!

លោកនិចសុនបង្ហាញលោក Kissinger ទៅលោកប្រធានម៉ៅ ថាជាដុកទ័រផ្នែកហ្វីឡូ ។ លោកម៉ៅសួរចំអកទៅលោកនិចសុនថា តើគួរឲ្យដុកទ័រហ្វីឡូនេះដើរតួធំប៉ុនណាដែរនៅក្នុងបន្ទប់នេះ ? រួចហើយលោកម៉ៅក៏និយាយចំអកបន្ថែមទៀតថា ៖

– ខ្ញុំឮថា លោកដុកទ័រហ្វីឡូហ្ស៊ីង ពូកែយុទ្ធសិល្បបោកចំបាប់ជាមួយស្រីៗខ្លាំងណាស់... នៅទីនេះមានទ័ពស្រីចិនរហ័សរហួន ដែលរង់ចាំតែសមយុទ្ធជាមួយលោកដុកទ័រហ្វីឡូប៉ុណ្ណោះ ដើម្បីកុំឲ្យអាប់ឱនកេរ្តិ៍ឈ្មោះដល់ស្រីចិន...

នៅពេលនោះ ស្រីៗចិនទាំងប៉ុន្មានដែលបំរើនៅក្នុងបន្ទប់ម៉ៅ-សេទុង ក៏នាំគ្នាសើចលាន់រំពង ។

★★★ លោកគីស្ស៊ីងគ្ញើរជាជនយូដា ដែលស្អប់លោកនិចសុនខ្លាំងណាស់ ។ មុនពេលបោះឆ្នោត លោកបានអះអាងថា លោកនិចសុន «មិនសក្តិសមធ្វើប្រធានាធិបតីទេ» (Unfitted to be President) ។ ប៉ុន្តែពេលលោកនិចសុនជាប់ឆ្នោតហើយ, លោកគីស្ស៊ីងគ្ញើរក៏ចូលមកបំរើសេតវិមានតាមទ្វារក្រោយ ដោយមានអ្នកជំនិតពីរនាក់របស់លោកនិចសុន លោក Haldeman និង Erlichman នាំចូលមក ។ បានសេចក្តីថា អ្នកទាំងពីរនាក់ក្រោយនេះជាជនក្បត់ដែរ... បានជានាំជនក្បត់ឲ្យមកជួបចៅហ្វាយនាយរបស់ខ្លួន ។ ជនយូដាមានរាយប៉ាយគ្រប់សញ្ជាតិ ហើយពួកគេជួយសហការគ្នាណាស់ ក្នុងប្រការពិឃាតលោកប្រធានាធិបតី, ពង្រាលដាលភ្លើងសង្គ្រាម, បង្ហូរឈាមជនស្លូតត្រង់ដែលគេហៅថា ៖ La juiverie inter nationale ។ រឿងដែលអកុសលគឺជនទាំងបីរូប Kissinger, Erlichman, Haldeman ក៏បានក្លាយទៅជាសម្តេចវាំងដំរេឆ្មើម ដែលរួតរឹតលោកប្រធានាធិបតីឲ្យដកដង្ហើមលែងកើត ។ ក្នុងចំណោមបីនាក់នោះ បើមានតែម្នាក់ស្មោះត្រង់ជាមួយលោកនិចសុន, របៀបលោកនល់-នល់ជាមួយសម្តេចសីហនុ ឬដូចជូ-អេនឡាយជាមួយម៉ៅ-សេទុង, លោកប្រធានាធិបតីនិចសុនមិនបានដួលរលំទៅណាដែរ... ប៉ុន្តែនេះគឺជាការក្បត់ទាំងក្រុមទាំងចង្កោមតែម្តង ។ ជាពិសេសលោកគីស្ស៊ីងគ្ញើរ ជនក្រៅបញ្ជីសោះនៅក្នុងរដ្ឋការនិចសុន បានចូលមកក្តោបក្តាប់កិច្ចការបរទេសនិងយោធារបស់សហរដ្ឋអាមេរិកទាំងមូល ប្រហែលគ្នានឹងប្រធានាធិបតីទី២, បានពង្រាលដាលភ្លើងសង្គ្រាមប្រល័យពូជសាសន៍ ចូលក្នុងទឹកដីកម្ពុជា ដើម្បីឲ្យមាតុភូមិខ្មែរធេះរួញក្រញង់ ធ្លាក់ចូលក្នុងប្លុកឥណ្ឌូចិន-វៀតណាម... បានបង្កើតរឿងវិបត្តិ

*Watergate ធាក់លោកប្រធានាធិបតីនិចសុន ធ្លាក់ចេញពីតំណែងយ៉ាងព្រងើយ... ដោយប្រមូលអំណាចរបស់លោកប្រធានាធិបតីទាំងអស់ យកមកក្តោបក្តាប់ក្នុងដៃរបស់ខ្លួនឯង...។ ថាប្រទេសខ្មែរចុះជាប្រទេសសក្តិភូមិ... ចុះសហរដ្ឋអាមេរិកដែលជាមហាអំណាចជឿនលឿន ក៏មានរដ្ឋប្រហារស្មោកគ្រោកដូចនេះដែរ ??*

❑ ❑ ❑

*★★★ នៅពេលដែលលោកនិចសុនដួលរលំភ្លាមទៅ ដូចយក្សមួយបាក់ជើងយ៉ាងគំហុក, មហាអំណាចទី១ក្នុងពិភពលោក ក៏ត្រូវកំបុតក្បាល ។ ចំពោះលោកនិចសុន សេចក្តីអកុសលនេះក៏ជាការល្អម្យ៉ាងដែរ... លោកមិនមែនជាប្រធានាធិបតីហ្វ័រដ ឬក៏«លោកប្រធានាធិបតីគីស្សីងគ្ន័រ»...។ សហរដ្ឋអាមេរិកក៏បានក្លាយទៅជាអំណាចទី៤...ក្រោមយួន, ក្រោមចិន, ក្រោមសូវៀត !!*

*ចុងចប់ទៅ, នេះជាសេចក្តីសារភាពទទួលកំហុសរបស់លោកគីស្សីងគ្ន័រ ចំពោះប្រទេសកម្ពុជា និងចំពោះលោកនិចសុន ៖ «ជាការសំខាន់ណាស់, គីស្សីងគ្ន័រពោល, ដែលសង្គ្រាមមិនត្រូវបញ្ចប់ ដោយគ្រាន់តែសហរដ្ឋអាមេរិក បោះបង់បោលប្រជាពលរដ្ឋ ដែលខ្លួនបានជំរុញឲ្យច្បាំងជាមួយនឹងកុម្មុយនិស្តតែប៉ុណ្ណោះទេ ។ តើនរណាដឹងថា Watergate បានធ្វើឲ្យអំណាចនីតិប្រតិបត្តិធ្លាក់ខ្សោយដំម៉្លេះ រហូតដល់យើងមិនអាចបំពេញនូវសន្យា ដែលធម្មតាយើងគួរតែបំពេញបាន» ។*

*ប៉ុន្តែលោក William Shawcross បានបញ្ចប់សៀវភៅរបស់លោក Side show ដោយសរសេរដូច្នេះថា ៖*

*«ប្រទេសកម្ពុជាមិនមែនជាកំហុស ឬជាការភ័ន្តច្រឡំនោះទេ... រឿងប្រទេសកម្ពុជា គឺជារឿងជាក់ស្តែងនៃបទឧក្រិដ្ឋកម្ម» ។*

❑ ❑ ❑

*<u>កក្កដា ១៩៦៩</u> ៖ ខ្លួនខ្ញុំមានវត្តមាននៅប្រទេសបារាំងនៅឡើយ ។ ខ្ញុំបានអានអត្ថបទមួយនៃទីភ្នាក់ងារ AFP ផ្ញើមកពីភ្នំពេញ ដែលមានសេចក្តីថា ៖ «សម្តេចសីហនុបានស្នើឲ្យលន់-នល់ដឹកនាំរដ្ឋាភិបាលថ្មីមួយ តែលន់-នល់បានបដិសេធ»*

*ពេលនោះ លោកលន់-នល់គាត់រាងចាល ។ គាត់មិនចង់ផ្តល់ឱកាសឲ្យស្តេចសម្លាប់គាត់ម្តងទៀតទេ...។ ម្យ៉ាងវិញទៀត លោកលន់-នល់មានលេសមួយដ៏សំខាន់ណាស់ ៖ គឺប្រពន្ធទី១របស់លោក, ជំទាវខេង, កំពុងកើតរោគមហារីកដល់ដំណាក់ការចុងក្រោយ... គ្មានផ្លូវសង្ឃឹមថាអាចរស់បានឡើយ ។ នៅលើគ្រែដំណេកនៃសេចក្តីស្លាប់, ជំទាវខេងបានផ្តាំលោកលន់-នល់ជាចុងក្រោយថា ៖ «កុំចង់ធ្វើធំ» បានសេចក្តីថា កុំឲ្យទទួលយកតំណែងអ្វីទាំងអស់ ដែលស្តេចសីហនុទ្រង់ប្រទាន ។ ប៉ុន្តែតើលន់-នល់អាចជំនះនឹងឆន្ទៈរបស់ស្តេចសីហនុបានឬទេ ??*

ការបដិសេធរបស់លន់-នល់ គឺជាការប្រមាថព្រះបេស្កាជ៏សំបើមណាស់ ។ ស្ដេចសីហនុមិនអាចទទួលការបាក់មុខបែបដូចនេះបានទេ...។ ទ្រង់ក៏បានបញ្ជូនម្ដាយក្មេកឈ្មោះយាយប៉ោមពាង (ម្ដាយអ្នកម្នាងម៉ូនិក) ទៅតថ្លៃជាមួយលោកលន់-នល់ចំនួន៧យប់៧ថ្ងៃ... ។ នៅទីបំផុត លោកនល់-នល់ក៏ទទួលយល់ព្រមបង្កើតរដ្ឋាភិបាលមួយហៅថា «រដ្ឋាភិបាលស្រោចស្រង់ជាតិ»... ដែលមានទ្រង់ស៊ីសុវត្ថិ-សិរិមតៈជារដ្ឋមន្ត្រីទី១-ទី២ ឬ«នាយករដ្ឋមន្ត្រីប្រតិភូ» ។ លោកលន់-នល់មិនបាច់ធ្វើអ្វីទេ គ្រាន់តែឈរតែឈ្មោះក៏បានដែរ... ទុកឲ្យទ្រង់សិរិមតៈធ្វើចំណាត់ការគ្រប់យ៉ាងនៃរដ្ឋាភិបាល...។ នេះគឺជាដៃយួន ក្នុងការរៀបចំទម្លាក់ស្ដេចសីហនុទេតើ... ដោយយកឈ្មោះលន់-នល់មកប្រើទៀតហើយ ពីព្រោះយាយប៉ោមពាងក៏ជាយួន ហើយទ្រង់សិរិមតៈក៏ជាយួន ! «រដ្ឋាភិបាលស្រោចស្រង់ជាតិ» ជារដ្ឋាភិបាលបន្តុបដោយសារយួន ដែលមានគោលបំណងសំខាន់ រុញច្រានប្រទេសកម្ពុជា ឲ្យធ្លាក់ក្នុងភ្លើងសង្គ្រាមប៉ុណ្ណោះ ។

សូមអានអត្ថបទមួយដកស្រង់ចេញពីសៀវភៅរបស់លោក Milton Osborne ដដែល (Sihanouk - Prince of light...) ត្រង់ចំណុចសិរិមតៈ p-199 ៖

«នៅពេលដែលឆ្នាំ១៩៦៨ មកដល់ចុងចប់ គេឃើញពួកក្រុមនយោបាយជាច្រើនកំពុងខ្នះខ្នែងទំប្រឹងពង្រឹងជំហររបស់ខ្លួន សំរាប់អនាគតមួយមិនច្បាស់លាស់ ។ ក្នុងប្រការនេះ ឈ្មោះអ្នកអង្គម្ចាស់ស៊ីសុវត្ថិ-សិរិមតៈលេចឡើងញឹកញាប់ជាងគេ ។ ជាបងប្អូនជីដូនមួយរបស់សីហនុ ហើយពីដើមជាអ្នកគាំទ្រព្រះអង្គ, សិរិមតៈបានប្រែក្លាយទៅជាអ្នករិះគន់នយោបាយរបស់សម្ដេច, ជាហេតុបណ្ដាលឲ្យទ្រង់ត្រូវឃ្លាតឆ្ងាយពីអំណាច, បញ្ជូនទៅកាន់ការបន្ទាប់បន្សំនៅបរទេសរាប់ឆ្នាំ (អគ្គរាជទូតខ្មែរនៅប៉េកាំង) ។ ប៉ុន្តែថ្វីបើរស់នៅក្នុងជីវិតនិរទេសបែបនេះក្ដី ទ្រង់សិរិមតៈនៅតែមានមុខមាត់សំខាន់ ពីព្រោះម៉ូនិកធ្លាប់ជំពាក់គុណទ្រង់ ធ្លាប់រស់នៅក្នុងផ្ទះទ្រង់ជាយូរឆ្នាំ...» ។

★★★ ដូចនេះ ការពិតលេចឡើងច្បាស់ក្រឡែត ។ អ្នកម្នាងម៉ូនិកជាកូនចិញ្ចឹមរបស់ទ្រង់សិរិមតៈទៅវិញសោះ ! ដូចនេះយាយប៉ោមពាងហើយនិងទ្រង់សិរិមតៈដែលលោកយាយទើបបានតែងតាំងឲ្យទៅជានាយករដ្ឋមន្ត្រីប្រតិភូរបស់លន់-នល់, អ្នកម្នាងម៉ូនិក, អ៊ុំ-ម៉ាណូរិន, សុស្ដែន-ហ្វែរណង់ដែស គឺជាក្រុមគ្រួសារតែមួយ ។ អ្នកម្នាងណាណែត បងស្រីអ្នកម្នាងម៉ូនិក ក៏មានប្ដីឈ្មោះថា ស៊ីសុវត្ថិ-មេធាវី ដែលត្រូវជាប្អូនបង្កើតរបស់ទ្រង់សិរិមតៈផងដែរ !

★★★ នៅក្នុងឆ្នាំ១៩៧២ នៅពេលដែលសាធារណរដ្ឋខ្មែរកំពុងជាប់ដៃច្បាំងវក់វីពេញទំហឹង ជាមួយយួនឈ្លានពានយៀកកុងនិងយៀកណាមខាងជើង, ទ្រង់

សិរិមតៈបានទទួលយកក្មួយប្រុសម្នាក់មកពីប៉េកាំង ទ្រង់ស៊ីសុវត្ថិ-ថូមីកូ ដែលត្រូវជាកូនរបស់មេធាវី-ណាណែត យកមកឲ្យធ្វើជាលេខាធិការពិសេស (SP) របស់លោកមេទ័ពសាធារណរដ្ឋសុស្តែន-ហ្វេរណង់ដែស ។ ដូចនេះ សិរិមតៈ, សុស្តែន, អ៊ុំ-ម៉ាណូរិន, ថូមីកូ... គឺដូចតែមួយដំបរទិន្នបួន, យួនឈ្នានពានតែមួយ

ដូចនេះ ពួកយួនឈ្នានពាន (សិរិមតៈ)... ឥតមានគិតអំពីចំណងគ្រួសារសាច់ឈាមក្រុមញាតិអ្វីទាំងអស់... ពួកគេគិតតែផលប្រយោជន៍ទឹកដីឲ្យតែបានចំណេញទៅវៀតណាមប៉ុណ្ណោះ ។ តាមពិតកូនស្រីចិញ្ចឹម ក៏ដូចតែកូនស្រីបង្កើត ។ ដូចនេះសិរិមតៈបានយកសម្រស់កូនស្រីរបស់ទ្រង់, អ្នកម្នាងម៉ូនិក, ទៅបំពល់ស្តេចសីហនុ ហើយក៏នាំគ្នាជេរស្តេចថាអាស្តេចឆ្កួត «ឈ្លក់នឹងកណ្តូ...ស្រីយួនទឹកបីវៃយកទឹកមួយ»... ដូចស្តេចជ័យជេដ្ឋាទី២អស់ទឹកដីកម្ពុជាក្រោម ។ ទាំងនេះជាមធ្យោបាយដំសក្តិសិទ្ធិរបស់ជនជាតិយួន ដើម្បីវាយប្រហារទៅលើកិត្តិយសស្តេចខ្មែរ ក្នុងប្រការបំផុសបំផុលប្រជារាស្ត្រឲ្យស្អប់ស្តេច រួចហើយប្ញទ់យកទឹកដីខ្មែរបណ្តោយ ។

★★★ តាមប្រកពច្បាស់ការណ៍ ព្រះកូណានរោត្តម-សីហនុ នៅក្នុងជន្មាយុ ៣០ឆ្នាំ បានទម្លាយព្រហ្មចារីយ៍របស់នាងកញ្ញា Monique Izi មានអាយុ១៥ឆ្នាំ (កាលនោះគឺឆ្នាំ១៩៥២ សម័យព្យុហយាត្រាសាមគ្គីទាមទារឯករាជ្យ) នៅផ្ទះអ្នកអន្តម្ចាស់សិរិមតៈ វិថីឧកញ៉ាផ្លុង មិនឆ្ងាយប៉ុន្មានពីព្រះរាជវាំង ។ កាលសម័យនោះមានបោះពុម្ពពាក្យស្លោកលើបដាធំៗ បិទគ្រប់ទីកន្លែងសាធារណៈ ក្រោយរូបភាពយុទ្ធជនខ្មែរដែលកំពុងក្រាបលូនក្រោមខ្សែលួសបន្លា នូវពាក្យដូច្នេះថា ៖ «ស៊ូស្លាប់ដើម្បីការពារជាតិមាតុភូមិ... កុំឲ្យតែស្លាប់នៅក្រោមអាចុចៗ» ។ ពាក្យទាំងនេះជាពាក្យជេរប្រមាថរបស់ជនជាតិយួន (ពួកសិរិមតៈ) ទៅលើស្តេចសីហនុទៅវិញសោះ ។

នៅក្នុងសម័យអតីតកាល (គ.ស១៦១៨) ស្តេចយួនក្រុងវ៉េ បានយកកូនស្រីរបស់ខ្លួន ព្រះនាងកូជិន មកបញ្ចុកបន្សី ព្រះជ័យជេដ្ឋាទី២... រួចហើយកងទ័ពយួនមកតាំងនៅស៊ើរគ្រប់ទីកន្លែងក្នុងមាតុភូមិខ្មែរ ។ ស្រីយួននោះបំពុលប្តីខ្លួនឯងឲ្យស្លាប់១០ឆ្នាំក្រោយមកតំបន់ទឹកដីខ្មែរកម្ពុជាក្រោមភាគច្រើន ដែលនៅជាប់នឹងទល់ដែននៃទឹកដីចំប៉ា, មានព្រៃគរ (ព្រៃនគរ), បារិយ៉ា (បារ៉ាយ), កំពាបស្រែកន្ទ្រើយ... បានធ្លាក់ទៅក្នុងកណ្តាប់ដៃយួនអស់ ។ រួចហើយជនជាតិយួនក៏វាយប្រហារលើកិត្តិយសស្តេចខ្មែរ ដោយបង្កើតពាក្យថា ជ័យជេដ្ឋាទី២បានប្រគល់ទឹកដីឲ្យយួនជាថ្នូរជាមួយនឹងព្រះនាងកូជិន ។

★★★ ទ្រឿង-មិញយ៉ាំង បានយកព្រះអង្គម្ចាស់ក្សត្រីអង្គមីរួចហើយ ក៏ដើរ

ផ្សាយពាក្យថា ស្តេចស្រីខ្មែរបានសាហាយស្មន់ជាមួយមេទ័ពយួន... ជាហេតុបណ្តាលឲ្យម្ចាស់ក្សត្រីអង្គម៉ីធ្លាក់ខ្លួនឆ្កួតលីលា !

★★★ លោកយ៉ែម-សំបូរ ដែលបានខ្លួនមហាក្សត្រីយានីកុសុមៈរួចហើយ (ក្នុងគោលបំណងបំបែកបំបាក់ស្តេចសីហនុ ជាមួយនិងម្តាយខ្លួនឯង) ក៏ដើរអួតអាងជេរស្តេចសីហនុថា «ឯងយកប្រពន្ធអញ... អញទរម៉ែអ្ហែង !»...

★★★ ក្នុងឆ្នាំ១៩៧៣, ស្រាប់តែសិរិមតៈបេះនឹកស្រណោះសាច់ឈាមក្រុមគ្រួសាររបស់ខ្លួនឯងដែរ គឺស្តេចសីហនុ, ជាប្អូនជីដូនមួយផង ជាកូនប្រសារផង (ព្រោះកូនស្រីម៉ូនិកជាប្រពន្ធសីហនុ) ។

★★★ នៅចុងឆ្នាំ១៩៧៣ ខ្ញុំបានស្នើឪពុកខ្ញុំ ឲ្យនាំខ្ញុំទៅជួបទ្រង់សិរិមតៈ ។ កាលពីក្នុងឆ្នាំ១៩៧០, ខ្ញុំធ្លាប់បានគោរពនិងស្រឡាញ់ទ្រង់សិរិមតៈ ស្មើគ្នានឹងលោកលន់-នល់ ។ ខ្ញុំធ្លាប់បានបំរើអ្នកទាំងពីរ ឲ្យទម្លាក់ស្តេចសីហនុ ។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៣, ខ្ញុំគាំទ្រតែសាធារណរដ្ឋ ហើយនិងឧត្តមសេនីយ៍លន់-នល់ប៉ុណ្ណោះ ហើយខ្ញុំស្អប់ខ្ពើមទ្រង់សិរិមតៈ ពីព្រោះទ្រង់កំពុងតែប្រើប្រាស់គ្រប់មធ្យោបាយទម្លាក់លោកលន់-នល់ ហើយយកស្តេចសីហនុមកវិញ ។ ចំពោះខ្ញុំ បើស្តេចសីហនុធ្វើត្រូវ, ម្តេចបានជាទម្លាក់លោក... ហើយបើស្តេចសីហនុធ្វើខុស ម្តេចបានជាចង់យកស្តេចត្រឡប់មកវិញ ? ហេតុអ្វីបានជាខ្ញុំចង់ជួបទ្រង់សិរិមតៈនៅពេលនោះ ពីព្រោះខ្ញុំចង់ផ្សះផ្សារទ្រង់សិរិមតៈហើយនិងលោកលន់-នល់ ឲ្យជានាគ្នាឡើងវិញ ពីព្រោះសភាពការណ៍នៃសាធារណរដ្ឋខ្មែរកំពុងតែធ្លាក់ដុនដាបខ្លាំងណាស់...

★★★ គ្រាន់តែឃើញមុខខ្ញុំភ្លាម ទ្រង់សិរិមតៈស្រាប់តែឆេះជុំ ដោយសារភ្លើងគំនុំពីចម្ងាយ ។ ទ្រង់ជេរប្រមាថលោកលន់-នល់ត្រង់ៗតែម្តង គឺហាក់ដូចជាជេរខ្ញុំដូចនោះឯង ៖

- លោកឃើញលន់-នល់ទេ, សំគិះ, គម្រក់ចាញ់ការដឹកនាំរបស់សម្តេចសីហនុឆ្ងាយណាស់... ហៅមិនឮ បើតែអញ្ចឹងតទៅទៀត ពួកខាងយើងច្បាស់ជាចាញ់ពួកខាងម្ខាងជាប្រាកដ !

(ប៉ុន្តែពាក្យដែលទ្រង់សិរិមតៈជេរលោកលន់-នល់នៅក្នុងឆ្នាំ១៩៧៣ គឺជាពាក្យដែលទ្រង់សិរិមតៈខ្លួនឯងធ្លាប់ជេរសម្តេចសីហនុកាលពីឆ្នាំ១៩៦៩... កាលនោះទ្រង់សិរិមតៈបានពោលថា «សម្តេចសីហនុឥឡូវជាមនុស្សឥតបានការ ឥតប្រ-យោជន៍ គ្មានធ្វើអ្វីទាំងអស់... ខុសគ្នាឆ្ងាយខ្លាំងណាស់ ពីសម្តេចសីហនុកាលសម័យទាមទារឯករាជ្យ») ។

...រំពេជនោះ ទ្រង់សិរិមតៈយួរស្បែកកំភួនដៃម្ខាងឡើងលើឲ្យខ្ញុំមើល រួចពោលថា ៖

– *ខ្ញុំជាស្តេចហ្នឹ៎... បើទោះគេយកកាំបិតមកអារស្បែករបស់ខ្ញុំ ក៏ខ្ញុំនៅតែជាស្តេច !!*

★★★ *ដូចពាក្យស្លោកបុរាណដែលនិយាយថា «កាត់ទឹកមិនដាច់ កាត់សាច់មិនបាន»... ទ្រង់សិរិមត:គឺមិនអាចអារស្បែកខ្លួនឯងជាស្តេចបោះចោលបានទេ !!*

★★★ *ចុះហេតុអ្វីបានជាទ្រង់សិរិមត: បានកាត់សាច់ខ្លួនឯងបោះឲ្យក្រពើស៊ីកាលពីឆ្នាំ១៩៦៩ ?? គឺទ្រង់បានកាត់ស្តេចសីហនុ បោះទៅឲ្យយៀកកុង !!*

★★★ *ខ្ញុំទើបនឹងបានដឹងថា ទ្រង់សិរិមត:ជាជនក្បត់កាល៦ខែមុនប៉ុណ្ណោះសោះ ។ គឺដោយត្រិះរិះពិចារណាទៅលើលិខិតចុងក្រោយរបស់ទ្រង់ ផ្ញើទៅលោក John Gunther Dean (ជនយូហ្វអាល្លឺម៉ង់ម្នាក់ ដែលជាកូនជីងរបស់គីស្ស៊ីងគ្គើរ... និងជាអគ្គរដ្ឋទូតអាមេរិកាំងចុងក្រោយប្រចាំនៅសាធារណរដ្ឋខ្មែរ)...*

*នៅក្នុងលិខិតនោះមានសេចក្តីបញ្ចប់ដ៏សំខាន់ដូច្នេះថា ៖*

*«...ខ្ញុំបានប្រព្រឹត្តកំហុសតែមួយគត់ គឺបានជឿពួកអស់លោក, ពួកអាមេរិកាំង» ។*

★★★ *បើបកស្រាយឲ្យចំទៅ... ទ្រង់សិរិមត:ចង់និយាយថា ៖ «ខ្ញុំបានប្រព្រឹត្តកំហុសតែមួយគត់ គឺបានឃុបឃិតជាមួយពួកអស់លោក, ពួកអាមេរិកាំង, ដើម្បីទម្លាក់សម្តេចសីហនុ កាលពីថ្ងៃទី១៨ មីនា ១៩៧០» ។៚*

❊ ❊

❊